ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យ ស្តីពី អាករលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩

---

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត /១១៩៨ /៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ. បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី អាករលើតម្លៃបន្ថែម
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

***សំរេច :***

*__មាត្រា ០១__* : មាត្រា ៣១ ( ស្តីពី អាករលើតម្លៃបន្ថែម លើធាតុចូលដែលមិនអនុញ្ញាតជាឥណទាន ) នៃ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម ត្រូវបានកែប្រែដូចខាងក្រោមនេះ :

" មាត្រា ៣១ - មិនត្រូវបានអនុញ្ញាតជាឥណទាន អតប លើធាតុចូលទេ ចំពោះ អតប ដែលបានបង់លើ :

ក -  ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់ អតប មានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ ។

ខ -  ការទិញ ឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់ អតប ប្រកបអាជីវកម្មជាអ្នកលក់ ឬ ជួលរថយន្ត ។

គ -  ការទិញ ឬ ការនាំចូលផលិតផលគេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់ អតប ប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលគេលសិលាទាំងនោះ ។

វៀរលែងតែមានចែងយ៉ាងណាផ្សេងវិញនោះ សំរាប់គោលដៅនៃអនុក្រឹត្យនេះ :

- ពាក្យ - ការទទួលភ្ញៀវ - មានន័យថា ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬ បដិសណ្ឋារកិច្ចណាមួយ ។
- ពាក្យ - រថយន្ត - សំដៅដល់រថយន្តសំរាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០ ។
- ពាក្យ - ផលិតផលគេលសិលា - សំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែរ ប្រេងម៉ាស៊ូត និងប្រេងរំអិល ។ ”

<u>មាត្រា ០២</u> : រាល់បទបញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>មាត្រា ០៣</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹតនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០០១

ហ៊ុន សែន

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ